# រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ ស្តីពី*

# ល្ខោនខោលវត្តស្វាយអណ្តែត
# បេតិកភណ្ឌវប្បធម៌អរូបីពិភពលោក



*ដោយ៖ បណ្ឌិត* **ផុន កសិកា**

*អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា*

*-ខែធ្នូ ឆ្នាំ២០១៨-*

# ល្ខោនខោលវត្តស្វាយអណ្តែត
# បេតិកភណ្ឌវប្បធម៌អរូបីពិភពលោក

*ដោយៈ បណ្ឌិត **ផុន កសិកា***

*អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

## សេចក្តីផ្តើម

*ល្ខោនខោល ឬ ភាណី ឬ ល្ខោនពាក់មុខ ជាប្រភេទសិល្បៈទស្សនីយភាពរបស់ខ្មែរមួយ ដែលមានអាយុកាលតាំងពីសតវត្សរ៍ទី១០[1]។ លក្ខណៈពិសេសរបស់ល្ខោនខោលគឺ សម្តែងតែនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរមួយគត់ (មិនយករឿងអ្វីផ្សេងមកសម្តែងឡើយ), អ្នកសម្តែងសុទ្ធតែប្រុសៗ (ទោះបីជាតួអង្គស្រីក៏យកប្រុសមកសម្តែងដែរ), សម្តែងពាក់មុខខ្នុក (ស្នាច់ពីក្រដាស) ជារបាំងមុខ ជារូបក្បាលតួអង្គផ្សេងៗ ដូចជា រូបក្បាលមេទ័ពស្វា ពលស្វា មេទ័ពយក្ស សេនាយក្ស តាឥសី ជាដើម។ មានវង់ល្ខោនខ្លះ សម្តែងតួដោយមិនពាក់មុខដែរ ប្រសិនបើតួអង្គមានរូបរាងជាមនុស្ស ដូចជាតួអង្គព្រះរាម ព្រះលក្សណ៍ នាងសេតា តែក្រុមខ្លះទៀតពាក់មុខខ្នុកទាំងអស់ ហើយត្រូវមានអ្នកពោលដំណើររឿងសាច់រឿងដោយចេះចាំស្ទាត់ ព្រមទាំងឆ្លើយឆ្លងពីតួអង្គមួយទៅតួអង្គមួយផង។ រីឯតួសម្តែង ត្រូវសម្តែងតាមក្បាច់របស់ខ្លួន និងត្រូវមានភ្លេងពិណពាទ្យមួយវង់ប្រគំកំដររហូតមិនដាច់តាមស្ថានភាពនៃសាច់រឿង។ ល្ខោនខោលឃើញមានសម្តែងក្នុងទំនៀមព្រះមហាក្សត្រ ដូចជាព្រះរាជពិធីឡើងសោយរាជ្យ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះរាជពិធីបុណ្យតាំងតុ ព្រះរាជពិធីបុណ្យអុំទូក ព្រះរាជពិធីចម្រើនព្រះកេសា (កោជុក) ព្រះរាជបុត្រ, ក្បួនព្រះរាជពិធីហែព្រះបរមសព ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព ព្រះរាជពិធីបួងសួងផ្សេងៗ។ល។ និងសម្តែងក្នុងទំនៀមអ្នកស្រុកទូទៅ ក្នុងពិធីបុណ្យបញ្ចុះសីមាឆ្លងព្រះវិហារ បុណ្យចម្រើនព្រះជន្មសម្តេចព្រះសង្ឃរាជ ឬចៅអធិការវត្ត បុណ្យថ្វាយព្រះភ្លើងព្រះសពសម្តេចព្រះសង្ឃរាជ បុណ្យរំលាយព្រះសពព្រះចៅអធិការវត្ត បុណ្យភូមិ (សុំទឹកភ្លៀង បណ្តេញចង្រៃ ឬជំងឺរាតត្បាត) ពិធីថ្វាយអ្នកតាអស់លោកបង់បទ និងទេពនានា ពិធីបួងសួង បន់ស្រន់ផ្សេងៗ ពិធីសំពះគ្រូ។ល។*

---

[1] ព្រាប ចាន់ម៉ារ៉ា ល្ខោនខោលនិងមុខខ្នុកនៅស្រុកខ្មែរ ២០១៨ ទំព័រ ៧

*ទម្រង់សិល្បៈបុរាណល្ខោនខោលដែលនៅរស់រានមានជីវិតរហូតដល់បច្ចុប្បន្ន មាន៤វង់ធំៗគឺៈ*

- *ល្ខោនខោលភ្នំពេញ*
- *ល្ខោនខោល ខេត្តបាត់ដំបង*
- *ល្ខោនខោល ខេត្តកំពង់ធំ និង*
- *ល្ខោនខោលវត្តស្វាយអណ្តែត ខេត្តកណ្តាល។*

*នៅថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ២០១៨ តាមសេចក្តីសម្រេច* Decision12.COM.10.a.3[2] *ល្ខោនខោលវត្តស្វាយអណ្តែត ដែលតំណាងឱ្យល្ខោនខោលនៅទូទាំងប្រទេសកម្ពុជា ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ដែលត្រូវការពារបន្ទាន់* (Need Urgent Safeguarding List)[3]*។*

*ក្នុងសេចក្តីដែលនឹងរៀបរាប់តទៅខាងមុខទៀតនេះ យើងនឹងបង្ហាញពីលក្ខណៈសម្បត្តិពិសេសដែលល្ខោនខោលវត្តស្វាយអណ្តែតបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដំណើរការនៃការចុះបញ្ជីបេតិកភណ្ឌ និងលក្ខណៈវិនិច្ឆ័យរបស់អង្គការយូណេស្កូ។*



រូបលេខ១៖ ការសម្តែងល្ខោនខោល (រូបភាពដោយ ព្រាប ចាន់ម៉ារ៉ា)

---

[2] សេចក្តីជូនដំណឹង ស្តីពី ការចុះល្ខោនខោលចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ជាសេចក្តីជូនដំណឹងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨

[3] កិច្ចសម្ភាសន៍លោក សាន ផល្លា ក្នុង www.km.rfi.fr

## លក្ខណៈសម្បត្តិពិសេសនៃល្ខោនខោលវត្តស្វាយអណ្ដែត

ល្ខោនខោលវត្តស្វាយអណ្ដែតត្រូវបានសម្ដែងដោយសហគមន៍មួយរស់នៅជុំវិញវត្តមួយ ឈ្មោះ **វត្តស្វាយអណ្ដែត** ស្ថិតនៅចម្ងាយជាង១០គីឡូម៉ែត្រ នៅតាមទន្លេមេគង្គ ខាងកើតរាជធានីភ្នំពេញ។ ល្ខោននេះសម្ដែងដោយពាក់មុខ (ខ្នុក) និងមានវង់ភ្លេងពិណពាទ្យអមជាមួយផង។ គោលបំណងនៃការសម្ដែងល្ខោននេះ គឺជាការបន់ថ្វាយដល់អ្នកតាដែលថែរក្សាការពារ នាំមកនូវសេចក្ដីសុខសម្បូរសប្បាយក្នុងសហគមន៍ ទឹកដី និងក៏ដើម្បីទទួលបានភោគផលល្អផងដែរ។ ដូច្នេះ ល្ខោនខោលវត្តស្វាយអណ្ដែតសម្ដែងក្នុងគោលបំណងថ្វាយដល់អ្នកតា ជាពិសេសសម្រាប់កសិកម្មនៅរៀងរាល់រដូវសម្រាប់តម្រូវការសហគមន៍ទាំងមូល[4]។

កិច្ចប្រតិបត្តិនេះធ្វើឡើងតាមរយៈការផ្សព្វផ្សាយតៗគ្នាក្នុងសហគមន៍ ហើយព្រះចៅអធិការវត្តព្រមទាំងលោកនាយកសាលាដែលចូលនិវត្តន៍ បានចាប់ផ្ដើមបើកថ្នាក់បង្រៀននៅចុងសប្ដាហ៍ និងចាប់សរសេរសាច់រឿងជាលាយលក្ខណ៍អក្សរ។ នៅពេលល្ខោនខោលកំពុងសម្ដែង អ្នកចូលរូបបានសម្រុះសម្រួលគ្នារវាងអ្នកតា តួសម្ដែង និងប្រជាជន។ នៅពេលអ្នកតាពេញចិត្តការសម្ដែងហើយនោះ ប្រជាជនត្រូវបានអ្នកតាប្រសិទ្ធពរជ័យឱ្យ។ ពេលនោះតួសម្ដែងក៏ឈប់សម្ដែង តែភ្លេងនៅបន្តលេង ហើយអ្នកទស្សនាក៏ស្ងាត់ស្ងៀម និងស្ដាប់អ្នកតាដោយយកចិត្តទុកដាក់។

ការសម្ដែងល្ខោនខោលមានលក្ខណៈជាកាតព្វកិច្ចប្រចាំឆ្នាំមួយរបស់សហគមន៍ចំណុះជើងវត្តស្វាយអណ្ដែត ហើយការប្រតិបត្តិនេះបានបន្តគ្នាពីជំនាន់មួយមកជំនាន់មួយរហូតដល់បច្ចុប្បន្ន។ ប៉ុន្តែ របបប្រល័យពូជសាសន៍ខ្មែរក្រហមបានធ្វើល្ខោនខោលវត្តស្វាយអណ្ដែតបានប្រឈមនឹងបញ្ហាជាច្រើនដោយចាស់ទុំ អ្នកដឹកនាំសម្ដែង និងអ្នកសម្ដែងជាច្រើនបានស្លាប់។ បច្ចុប្បន្នបញ្ហាបរិស្ថានសង្គម កង្វះធនធាន និងចំណាកស្រុក កំពុងធ្វើឱ្យស្ថានភាពល្ខោនខោលវត្តស្វាយអណ្ដែតប្រឈមនឹងការបាត់បង់នៅពេលខាងមុខ។ ស្ថានភាពនេះគឺទាមទារឱ្យរាជរដ្ឋាភិបាល យកចិត្តទុកដាក់រកវិធីដើម្បីអភិរក្សឱ្យបានគត់មត់។

ការដាក់បញ្ចូលល្ខោនខោលវត្តស្វាយអណ្ដែតជាសម្បត្តិបេតិកភណ្ឌពិភពលោក មិនមែនមានន័យថាយើងដាក់តែល្ខោនខោលវត្តស្វាយអណ្ដែតនោះទេ គឺល្ខោនខោលវត្តស្វាយអណ្ដែតជា

[4] https://ich.unesco.org/en/USL/lkhon-khol-wat-svay-andet-01374

តំណាងឱ្យល្ខោនខោលទូទាំងប្រទេស។ ដោយនៅក្នុងគោលការណ៍របស់យូណេស្កូ តម្រូវឱ្យមានសហគមន៍មួយតំណាង ហើយរាជរដ្ឋាភិបាលកម្ពុជាយល់ថា ល្ខោនខោលនៅសហគមន៍ស្វាយអណ្តែតស័ក្តិសមបំផុតនឹងគោលការណ៍នេះ ខណៈដែលវង់ល្ខោនខោលនៅទីផ្សេងៗសម្តែងគ្រាន់តែកំសាន្ត។ ឧទាហរណ៍ល្ខោនខោលនៅបាត់ដំបងសម្តែងនៅពេលគេជួលយកទៅសម្តែង។ ល្ខោនខោលនៅសហគមន៍ស្វាយអណ្តែត មានលក្ខណៈពិសេសដោយសារការសម្តែងមិនមែនសម្រាប់រកប្រាក់កម្រៃទេ ល្ខោនខោលនេះនៅជាប់ជាមួយជំនឿយ៉ាងមុតមាំរបស់អ្នកស្រុក ដើម្បីបួងសួងសុំសេចក្តីសុខចម្រុងចម្រើន បញ្ចៀសឧបទ្រពចង្រៃ ពិសេសនោះ គឺបានទទួលទឹកភ្លៀងគ្រប់គ្រាន់ និងភោគផលបរិបូរណ៍សម្រាប់រដូវដាំដុះខាងមុខ[5]។

ដោយការសម្តែងត្រូវប្រព្រឹត្តទៅជារៀងរាល់ឆ្នាំមិនដែលខាន ទោះបីជីវភាពក្រីក្រយ៉ាងណាក្តី ការសម្តែងល្ខោនខោលបានក្លាយជាកាតព្វកិច្ចរបស់អ្នកភូមិស្វាយអណ្តែត។ ល្ខោនខោលមានប្រវត្តិយូរមកហើយ និងបានបន្តវេនពីជំនាន់មួយទៅជំនាន់មួយរាប់ជំនាន់ ហើយស្ថិតក្នុងវត្តជាទីកន្លែងថែទាំអក្សរភិរក្សដែលអ្នកស្រុកមកហាត់ល្ខោននៅក្នុងវត្តនេះតែម្តង។

ចំពោះអ្នកស្រុកខ្លួនឯងផ្ទាល់យល់ថា ល្ខោននេះជាមរតកវប្បធម៌របស់ខ្លួន ហើយខិតខំព្យាយាមការពារតាមលទ្ធភាពដែលអាចធ្វើទៅបាន។ អ្នកស្រុកគិតថា ការសម្តែងគឺជាកាតព្វកិច្ចរបស់អ្នកស្រុកទាំងមូល ដោយខ្លះជួយជាធនធាន ខ្លះជួយជាកម្លាំង។ លក្ខណៈពិសេសមួយទៀតនៃល្ខោនខោលវត្តស្វាយអណ្តែតគឺ សហគមន៍មានជំនឿគោរពបូជាខ្លាំងចំពោះអ្នកតាឈ្មោះ «កំហែង» ដែលគេយល់ថា អ្នកតាកំហែងជាតួអង្គហនុមាន[6]ក្នុងល្ខោនខោលវត្តស្វាយអណ្តែតនេះ។ អ្នកស្រុកមានជំនឿខ្លាំងលើអ្នកតា «កំហែង» ដោយមានការបន់ស្រន់ដល់អ្នកតាដើម្បីសុំសេចក្តីសុខ បញ្ចៀសឧបទ្រពចង្រៃ ហើយក៏បន់សុំឱ្យប្រកបមុខរបរកសិកម្មបានភោគផលច្រើននៅឆ្នាំខាងមុខៗ។

ការចុះបញ្ជីល្ខោនខោលវត្តស្វាយអណ្តែតក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ជាបេតិកភណ្ឌតំណាងឱ្យល្ខោនខោលនានាក្នុងប្រទេសកម្ពុជាទាំងមូល។ ទោះបីយើងចុះក្នុងបញ្ជីការពារបន្ទាន់

---

[5] ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា ( Inventory of Cultural Heritage of Cambodia ) ឆ្នាំ២០១៦, ទំព័រ ១២២

[6] ក្នុងការសម្តែងល្ខោនខោល ពាក្យរបស់អ្នកពោលដំណើររឿងជួនកាលពោលថា «កំហែងហនុមាន» គឺសំដៅលើហនុមាន។ ជួនកាលពោលថា «កំហែង» ក៏សំដៅលើហនុមានដែរ។

*ប៉ុន្តែនៅពេលណាមួយយើងថែទាំបានល្អ លែងប្រឈមនឹងការបាត់បង់ យើងអាចស្នើបញ្ចូលក្នុងបញ្ជីតំណាង* (Representative List) *នៅពីរ ឬបីឆ្នាំក្រោយមកទៀត។*



រូបលេខ២៖ ល្ខោនខោលវត្តស្វាយអណ្តែត (ប្រភព៖ https://www.youtube.com/watch?v=M6ZhRxs8AJ4)

## ដំណើរការចុះបញ្ជីល្ខោនខោល

*ការចុះបញ្ជីល្ខោនខោលវត្តស្វាយអណ្តែតក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌអរូបីពិភពលោកត្រូវបានរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលគេហៅថាភាគីរដ្ឋជាម្ចាស់សម្បត្តិ* (State Party) *ជាតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា។ នៅពេលដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានសម្រេចចិត្តថាដាក់ល្ខោនខោលវត្តស្វាយអណ្តែតចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីពិភពលោក ក្រសួងក៏ចាប់ផ្តើមសិក្សាស្រាវជ្រាវបន្ថែមចងក្រងឯកសារតាំងពីឆ្នាំ២០១៥។ នៅឆ្នាំ២០១៦ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក៏រៀបចំបញ្ចូលល្ខោនខោលនេះទៅក្នុងបញ្ជីត្រៀម* (Tentative List) *ក្នុងក្របខណ្ឌជាតិក្នុងបញ្ជីបេតិកភណ្ឌនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ដំណាក់កាលនេះក៏ជាលក្ខខណ្ឌរបស់អង្គការយូណេស្កូដែលតម្រូវឱ្យភាគីរដ្ឋម្ចាស់សម្បត្តិដាក់បញ្ចូលសម្បត្តិវប្បធម៌របស់ខ្លួនក្នុងបញ្ជីបេតិកភណ្ឌជាតិរបស់ខ្លួនមុននឹងស្នើដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ រហូតដល់ខែមីនា ឆ្នាំ២០១៧ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក៏បានដាក់ឯកសារស្នើសុំចុះល្ខោនខោលវត្តស្វាយអណ្តែតក្នុងបញ្ជីបេតិកភណ្ឌការពារបន្ទាន់ទៅអង្គការយូណេស្កូ។*

ឯកសារដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដាក់ស្នើទៅនោះ មិនត្រឹមជាឯកសារបច្ចេក-ទេសអំពីល្ខោនខោល តាមទម្រង់នានារបស់អង្គការយូណេស្កូតែប៉ុណ្ណោះទេ អង្គការយូណេស្កូ តម្រូវឱ្យមានឯកសារអមដែលជាលិខិតរបស់តំណាងសហគមន៍ជានាអះអាងថាសហគមន៍អនុញ្ញាតឱ្យចុះបញ្ជីល្ខោនខោលវត្តស្វាយអណ្ដែតផងដែរ។ ក្នុងនោះមានសមាជិកតំណាងដែលពាក់ព័ន្ធនឹងល្ខោនខោលវត្តស្វាយអណ្ដែត មានដូចជា៖ គ្រូបង្ហាត់ល្ខោនខោល ព្រះគ្រូចៅអធិការវត្តស្វាយអណ្ដែត គណៈគ្រប់គ្រងក្រុមល្ខោនខោលវត្តស្វាយអណ្ដែត និងមេភូមិតំណាងប្រជាពលរដ្ឋ។ ពួកគាត់បានសរសេរជាលិខិតដោយមានស្នាមមេដៃផងនោះ ដោយមានខ្លឹមសារថាយល់ព្រមទទួលចុះបញ្ជីល្ខោនខោលវត្តស្វាយអណ្ដែតក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

តាមបែបបទ និងនីតិវិធីរបស់អង្គការយូណេស្កូតម្រូវឱ្យភាគីរដ្ឋជាម្ចាស់សម្បត្តិដាក់ឯកសារនៅខែមីនា ហើយបន្ទាប់មកទៀត ក្រុមអ្នកជំនាញរបស់អង្គការយូណេស្កូដែលមានសមាជិកចំនួន ២៤ប្រទេស ចាប់ផ្ដើមសិក្សាឯកសារដែលបានដាក់ស្នើនោះទៅតាមពេលវេលា និងកាលវិភាគកំណត់ច្បាស់លាស់។ រហូតដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨នេះ ទើបអង្គការយូណេស្កូសម្រេចបញ្ចូលល្ខោនខោលវត្តស្វាយអណ្ដែតក្នុងសម្បត្តិបេតិកភណ្ឌអរូបីពិភពលោកដែលត្រូវការការពារបន្ទាន់ (the List of Intangible Cultural Heritage in Need of Urgent Safeguarding)។



៣.៣. **ល្ខោនខោល**

*Lkhon Khol (Male Masked Theatre)*

| | |
|---|---|
| សហគមន៍ ឬទីតាំងប្រតិបត្តិ | វត្តស្វាយអណ្ដែត, ក្រុមល្ខោនខោលរបស់លោកតា ជា ហ៊ា នៅខេត្តបាត់ដំបង, ក្រុមយុវជនល្ខោនខោលកម្ពុជា, នាយកដ្ឋានទស្សនីយភាពនិងសាលាមធ្យមវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ប្រភេទ | សិល្បទស្សនីយភាព |
| ពេលវេលា | ក្រោយចូលឆ្នាំ (វត្តស្វាយអណ្ដែត), មិនកំណត់ពេល (ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមលោកតា ជា ហ៊ា) |

**ពិពណ៌នា**

"ល្ខោនខោល" ជាល្ខោនមួយបែបដែលពាក់មុខខ្នុកសម្ដែង ហើយជាទូទៅតួអង្គសុទ្ធតែមនុស្សប្រុស និងសម្ដែងតែឈុតឆាកក្នុងរឿងរាមកេរ្តិ៍ប៉ុណ្ណោះ។ ល្ខោននេះធ្វើកាយវិការតាមសំឡេងពោល ហើយកំដរដោយភ្លេងពិណពាទ្យ។ សម្លៀកបំពាក់ និងគ្រឿងអលង្ការសម្រាប់លេងល្ខោនខោលវិញក៏មានភាពប្រណីតពុំខុសពីល្ខោនព្រះរាជទ្រព្យប៉ុន្មានទេ មិនថាល្ខោនខោលនោះជារបស់អ្នកក្រុង ឬរបស់អ្នកស្រុកស្រែចម្ការឡើយ។

ផ្អែកទៅលើការសិក្សាតាមរយៈសិលាចារឹកបុរាណ អ្នកស្រាវជ្រាវយល់ថាល្ខោនខោលមានដើមកំណើតពីល្ខោន "ភាណិ" ឬ "ភាន្ទិ" ជាប្រភេទល្ខោនដែលមានអ្នកពោលរៀបរាប់សាច់រឿង ហើយឃើញមានយ៉ាងហោចណាស់ក៏ចាប់ពីសម័យអង្គរ (ស.វ.៩-១២) មកដែរ។

យើងសង្កេតឃើញថា ល្ខោនខោលដែលសម្ដែងសព្វថ្ងៃមានពីរបែប ម៉្យាងគឺដើម្បីកម្សាន្ត ឬជាប់នឹងកិច្ចសាសនាបន្តិចបន្តួច និងល្ខោនខោលដែលនៅជាប់ក្នុងជំនឿរបស់សហគមន៍។ ល្ខោនខោលប្រភេទទី១នោះ មានដូចជាក្រុមល្ខោនលោកតា ជា ហ៊ា នៅខេត្តបាត់ដំបងដែលជាក្រុមសម្រាប់ជួលសម្ដែងកម្សាន្តក្នុងពិធីបុណ្យទាននានា។ ចំណែកនៅរាជធានីភ្នំពេញ មានក្រុមល្ខោនខោលនៃនាយកដ្ឋានសិល្បទស្សនីយភាព និងសាលាមធ្យមវិចិត្រសល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមល្ខោនខោលរបស់យុវជនល្ខោនខោលកម្ពុជា ដែលច្រើនតែសម្ដែងសម្រាប់លើកតម្កើងល្ខោនខោល និងលេងកម្សាន្តក្នុងឱកាសពិសេសនានាក្នុងកម្រិតជាតិ។

ចំណែកល្ខោនប្រភេទទី២នោះ គឺជាប់ជាពិសេសជាមួយសហគមន៍វត្តស្វាយ

រូបលេខ៣៖ ផ្នែកនៃបញ្ជីបេតិកភណ្ឌអរូបីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**Nomination file No. 01374**
**for inscription in 2018 on the List of Intangible Cultural Heritage**
**in Need of Urgent Safeguarding**

## A. State(s) Party(ies)

*For multi-national nominations, States Parties should be listed in the order on which they have mutually agreed.*

Cambodia

## B. Name of the element

### B.1. Name of the element in English or French

*Indicate the official name of the element that will appear in published material.*

*Not to exceed 200 characters*

Lkhon Khol Wat Svay Andet

រូបលេខ២៤៖ ឯកសារដែលក្រសួងវប្បធម៌ វិចិត្រសិល្បៈដាក់ស្នើទៅអង្គការយូណេស្កូ




រូបលេខ២៥៖ លិខិតលោក អ៊ឹម សារួន និង លោក ម៉ិច មាន ដាក់អមជាមួយឯកសារដាក់ស្នើទៅអង្គការយូណេស្កូ

( ប្រភព៖ https://ich.unesco.org/en/USL/lkhon-khol-wat-svay-andet-01374 )

**លក្ខណៈវិនិច្ឆ័យរបស់អង្គការយូណេស្កូ**

*នៅក្នុងយូណេស្កូមានបញ្ជី៣ ដែលជាបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ៖*

*១. បញ្ជីថៃទាំល្អ* (Best Practice List),

*២. បញ្ជីតំណាង* (Representation List) *និង*

*៣. បញ្ជីត្រូវការពារបន្ទាន់* (Need Urgent Safeguarding List)។

*បញ្ជីទាំងបីមានគុណតម្លៃដូចគ្នា គឺជាបញ្ជីដែលយូណេស្កូទទួលស្គាល់ទាំងអស់ មិនមានន័យថាបញ្ជីណាអន់ ឬបញ្ជីណាមួយល្អជាងបញ្ជីណាមួយទេ។ ករណីដែលយើងថៃបានល្អដោយកាតីវដ្ដខ្លួនឯងហើយ ត្រូវស្នើដាក់បញ្ចូលក្នុងបញ្ជីថៃទាំល្អ* (Best Practice List)។ *តែបើយើងត្រូវការពារបន្ទាន់ យើងត្រូវស្នើដាក់ក្នុងបញ្ជីមួយដែលហៅថាបញ្ជីការពារបន្ទាន់* (Need Urgent Safeguarding List)។

*នៅលើសកលលោក ដោយសារសកលភាវូនីយកម្ម មានចំណាកស្រុកទៅរកការងារធ្វើចំណែកយុវជនភាគច្រើនដែលមិនសូវចាប់អារម្មណ៍លើទម្រង់សិល្បៈបុរាណ ដូច្នេះហើយធ្វើឱ្យបេតិកភណ្ឌវប្បធម៌ ប្រពៃណីរបស់ខ្លួនត្រូវប្រឈមនឹងការរលំរលាយ ឬអាចបាត់បង់ទាំងនៅប្រទេសធំៗ កុំថាឡើយស្រុកតូចតាចដូចកម្ពុជា សូម្បីប្រទេសបារាំង ប្រទេសចិន ប្រទេសប្រេស៊ីល ក៏មានការចុះក្នុងបញ្ជីសម្បត្តិបេតកកណ្ឌអរូបីក្នុងបញ្ជីការពារបន្ទាន់ដែរ។ ការដាក់បញ្ចូលបេតិកភណ្ឌអរូបីមួយក្នុងបញ្ជីការពារបន្ទាន់ មិនមែនមានន័យថា បេតិកភណ្ឌនោះអន់នោះទេ គឺដោយសារសម្បត្តិនោះអាចនឹងជួបប្រទះការបាត់បង់ ដែលយើងត្រូវការការពារ។*

*ការដាក់បញ្ចូលក្នុងបញ្ជីនេះគឺជាការទាក់ទាញការយកចិត្តទុកដាក់ទាំងក្នុងមជ្ឈដ្ឋានជាតិនិងអន្តរជាតិឱ្យមករួមគ្នា ដើម្បីចាប់អារម្មណ៍លើបេតិកភណ្ឌមួយនេះ។ ក្នុងគណៈកម្មការរដ្ឋាភិបាលទាំង២៤ប្រទេស ដែលជាអ្នកវាយតម្លៃមរតកវប្បធម៌ដែលបានដាក់ស្នើទៅយូណេស្កូ មិនមែនវាយតម្លៃឱ្យចំណាត់លេខ១ លេខ២ ឬលេខ៣ទៅមរតកវប្បធម៌ណាមួយ ឬក៏ដាក់មរតករបស់ប្រទេសមួយអន់ជាងមរតកប្រទេសណាមួយនោះទេ គឺមរតកនីមួយៗមានតម្លៃស្មើគ្នាទាំងអស់។ មរតកបេតិកភណ្ឌរបស់ប្រទេសនីមួយៗមានតម្លៃផ្សេងៗ និងដោយឡែកៗពីគ្នា។*

*រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាបានចុះបញ្ជីមរតកបេតិកភណ្ឌទាំងរូបី និងអរូបីចំនួន៨មកហើយ គឺប្រាសាទអង្គរវត្តនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២, របាំព្រះរាជទ្រព្យនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ*

២០០៣, ល្ខោនស្បែកធំនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥, ប្រាសាទព្រះវិហារនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨, ល្បែងទាញព្រ័ត្រនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥, ចាប៉ីដងវែងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦, ប្រាសាទសម្បូរព្រៃគុកនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ និងល្ខោនខោលវត្តអណ្ដែតក្នុងបញ្ជីបេតិកភណ្ឌការពារបន្ទាន់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ។ ចំពោះចាប៉ីដងវែងវិញត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ក្នុងបញ្ជីការពារបន្ទាន់ (Need Urgent Safeguarding List)[7] ដូចគ្នានឹងល្ខោនខោលនេះដែរ។

## សេចក្ដីសន្និដ្ឋាន

ការចុះបញ្ជីនេះមានន័យថា អន្តរជាតិទទួលស្គាល់ថាក្រុមល្ខោនខោលវត្តស្វាយអណ្ដែតជាសម្បត្តិបេតិកភណ្ឌអរូបីពិភពលោកមួយដែរ តែសម្បត្តិមួយនេះប្រឈមនឹងការបាត់បង់ បើទុកណាជាអ្នកស្រុកផ្ទាល់ និងរដ្ឋអំណាចព្យាយាមថែរក្សាក៏ដោយ។ នេះគ្រាន់តែជាជំហានមួយនៃការចាប់ផ្ដើមនៃកិច្ចការថែរក្សាទ្រទ្រង់ឱ្យល្ខោនខោលវត្តស្វាយអណ្ដែតបាននៅគង់វង្ស។ កិច្ចការអភិរក្សទ្រទ្រង់ក្រុមល្ខោននេះ មិនមែនជាកាតព្វកិច្ចរបស់សហគមន៍វត្តស្វាយអណ្ដែតតែឯង ឬជាកាតព្វកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនោះទេ តែវាជាកាតព្វកិច្ចរបស់ជនកម្ពុជាគ្រប់រូប និងមនុស្សជាតិទូទៅផងដែរ។

ប្រទេសកម្ពុជាក៏ដូចជាប្រជាពលរដ្ឋកម្ពុជាទាំងអស់គួរមានមោទនភាពចំពោះជាតិខ្មែរដែលទទួលបានការទទួលស្គាល់ពីអន្តរជាតិនូវមរតកវប្បធម៌របស់ខ្មែរដែលដូនតាបានខិតខំថែរក្សាទុកឱ្យកូនចៅជំនាន់ក្រោយ។ ប្រជាពលរដ្ឋ ខ្មែរត្រូវនាំគ្នាជួយលើកតម្លៃ និងគាំទ្រសិល្បៈល្ខោនខោលមួយនេះតាមគ្រប់មធ្យោបាយ តាមរូបភាពផ្សេងៗ ដោយការចូលរួមឧបត្ថម្ភ ចូលទស្សនា ដូចជាមានសម្ដែងគួរតែចូលទស្សនា ជួយផ្សព្វផ្សាយ ក៏ដូចជាការចូលហាត់រៀនល្ខោនខោល ដើម្បីចូលរួមចំណែករក្សាមរតកនេះឱ្យបានបិតបេរតរៀងទៅ។

នៅឆ្នាំខាងមុខ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរួមសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតនឹងរៀបចំឯកសារ ស្នើដាក់បញ្ចូលសម្បត្តិបេតិកភណ្ឌជាតិខ្មែរមួយចំនួនទៀតទៅក្នុងបញ្ជី

[7] https://ich.unesco.org/en/USL/chapei-dang-veng-01165

សម្បត្តិបេតិកភណ្ឌពិភពលោក ដើម្បីអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិខ្មែរ ទុកជាអត្តសញ្ញាណ និងជាកិត្យានុភាពរបស់ជាតិ៕

**ឯកសារយោង**


១-កិច្ចសម្ភាសន៍លោក សាន ផល្លា ក្នុង www.km.rfi.fr (ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨)

២-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា (Inventory of Cultural Heritage of Cambodia) ឆ្នាំ២០១៦។

៣-ព្រាប ចាន់ម៉ារ៉ា ល្ខោនខោលនិងមុខខ្នុកនៅស្រុកខ្មែរ ២០១៨

៤- Lkhon Khol Wat Svay Andet ក្នុង https://ich.unesco.org/en/USL/lkhon-khol-wat-svay-andet-01374

៥- ល្ខោនខោលវត្តស្វាយអណ្តែត ក្នុង https://www.youtube.com/watch?v=M6ZhRxs8AJ4

៦- Chapei Dang Veng in https://ich.unesco.org/en/USL/chapei-dang-veng-01165